+855 (0)17774864
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

សា-សាបាសាក់ SA SA BASSAC

# ក្នុងក្លឹប
## ដោយ  អ៊ុក សុជីវី

សុជីវី កើតនៅក្នុងទីក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩៨៤។ នាង គឺជាប្រជាជនម្នាក់ ក្នុងចំណោមប្រជាជនចំនួន ៧០% នៅក្នុងប្រទេសកម្ពុជា ដែលមានអាយុក្រោម ៣០ ឆ្នាំ។ នាងបានធំដឹងក្តីក្នុងអំឡុងពេលដែលកម្ពុជាទើបចាប់ផ្តើមដំណើរការអភិវឌ្ឍន៍ប្រទេស និងទីក្រុង។ នាងត្រូវបានគេស្គាល់ តាមរយៈស្នាដៃគំនូររបស់នាង ដែលបង្ហាញពីយុវជនយុវនារីខ្មែរមួយក្រុម ដែលគេនិយមហៅថា ហ្វ្រែស្សី។ ដោយត្រូវបានគេចាត់ទុកថាជាស្ទីល និងអត្តសញ្ញាណមួយផុសចេញពីតម្រូវការនៃកម្មវិធីប្រកួតប្រជែងទេពកោសល្យនានាដែលផ្សាយតាមកញ្ចក់ទូរទស្សន៍ជាញឹកញាប់ ក្រុមហ្វ្រែស្សីបាននាំចូលមកក្នុងប្រទេសកម្ពុជានូវនិន្នាការនៃសម្ផស្ស និងម៉ូតពេញនិយមអន្តរជាតិពីបណ្តាប្រទេសជិតខាងក្នុងអាស៊ី។

គំនូរ *ក្នុងក្លឹប* ទាំង ១១ ផ្ទាំង ត្រូវបានពិពណ៌នាដោយចំណងជើងច្បាស់ៗ និងបង្ហាញឱ្យឃើញពីតួអង្គ និងបែបផែននៃវប្បធម៌ក្នុងក្លឹបរបស់ប្រទេសកម្ពុជា។ ក្លឹបជាច្រើន ក៏ជាបារ ឌីស្កូ កន្លែងដើរបង្ហាញម៉ូត និងកន្លែងសម្រាប់កម្មវិធីសម្តែងកម្សាន្តផងដែរ ដូច្នេះម៉ូតនិងស្ទីលមានសារៈសំខាន់យ៉ាងខ្លាំងចំពោះជីវិតពេលរាត្រី ដែលធ្វើឱ្យអ្នកទាំងឡាយប្រែក្លាយពីអ្នកទស្សនា ទៅជាអ្នកកម្សាន្ត ឬអ្នកសម្តែង។

វិធីសាស្ត្រផ្ទាល់របស់សុជីវី ចំពោះបច្ចេកទេស និងតួអង្គនៅក្នុងគំនូររបស់នាង គឺជាការអនុវត្តន៍ដែលបន្សល់ទុកពីជីតារបស់នាង ឈ្មោះលោកតា ស្វាយ គេន (១៩៣៣-២០០៩) ដែលគេតែងហៅថាជា ជីតានៃសិល្បៈសហសម័យ នៅក្នុងប្រទេសកម្ពុជា។ មរតកនៃជំនាញនេះបានឱ្យនាងបន្តនូវគោលបំណងរបស់លោកតា ស្វាយ គេន ក្នុងការរក្សាទុកនូវកំនត់ត្រានៃជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្មែរ សម្រាប់មនុស្សជំនាន់ក្រោយគ្រប់រូប។ ដោយឡែក គំនូររបស់សុជីវីមានភាពឃ្លាតឆ្ងាយពីគំនូររបស់លោកតា ស្វាយ គេន ដែលឆ្លុះបញ្ចាំងពីរឿងរ៉ាវផ្ទាល់ខ្លួន នៃបទពិសោធន៍ជីវិតដ៏ស្មុគស្មាញជាង ៦០ ឆ្នាំ របស់លោកតា។ ឥលូវនេះ ក្នុងវ័យ ២៧ ឆ្នាំ សុជីវី គូរពីជីវិតប្រចាំថ្ងៃក្នុងសម័យកាល*របស់នាង*។

តួអង្គនៅក្នុងគំនូររបស់ សុជីវី កើតចេញពីប្រភពជាច្រើនដូចជា រូបថតដែលកាត់ចេញពីទស្សនាវដ្តី, ការចុះទស្សនាផ្ទាល់ទៅកាន់ក្លឹបរាត្រីពេញនិយមនានានៅក្នុងទីក្រុងភ្នំពេញ (ស្ប៉ាក រ៉ក់ និងក្លាស៊ីក) និងការស្រមើស្រមៃរបស់នាង។ ខណៈពេលដែលវិចិត្រករល្បីៗនាពេលបច្ចុប្បន្នគូរគំនូរទៅតាមបែបផែន ហើយបង្ហាញពីវប្បធម៌ដែលពួកគេចង់ឆ្លុះបញ្ចាំង គំនូររបស់សុជីវីគឺមានលក្ខណៈលើសពីការបង្ហាញពីឧស្សាហកម្មកម្សាន្តសប្បាយនេះទៅទៀត។ សុជីវី មិនមែនត្រឹមតែជាវិចិត្រករប៉ុណ្ណោះទេ នាងហាក់បីដូចជាអ្នកច្នៃម៉ូតផងដែរ។ នាងគូរពីឥរិយាបថរបស់តួរអង្គរួចហើយ ទើបគូរម៉ូតសក់ សម្លៀកបំពាក់ គ្រឿងលំអ និងគ្រឿងសំអិតសំអាងខ្លួនតាមក្រោយ។ ចុងក្រោយ គំនូររបស់នាងបង្ហាញពីទំនាក់ទំនងមួយនៅក្នុងការបង្ហាញពីវប្បធម៌របស់យុវជនដែលស្វែងចេញពីខ្លួនឯង នៅក្នុងអំឡុងពេលដែលប្រទេសកំពុងស្ថិតក្នុងដំណាក់កាលប្រែមុខមាត់។

អំពីវិចិត្រករ៖ អ៊ុក សុជីវី (កើតក្នុងឆ្នាំ ១៩៨៤) គឺជាវិចិត្រករ ដែលគេស្គាល់តាមរយៈរូបគំនូរពីយុវជនខ្មែរ ដែលមានលក្ខណៈដូចគំនូរគូរដោយក្មេង។ *ក្នុងក្លឹប* គឺជាពិព័រណ៍តែម្នាក់ឯងលើកទី ២ របស់សុជីវី បន្ទាប់ពីពិព័រណ៍ *នឹងមានបន្ត* ដែលបានតាំងនៅវិចិត្រសាលនៃមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា ទីក្រុងភ្នំពេញ (២០០៩)។ ការតាំងពិព័រណ៍ជាក្រុមរួមមាន *កសិករនិងហ្វ្រែស្សី* នៅវិចិត្រសាល ស-ស ទីក្រុងភ្នំពេញ (២០១០) និង *តាំងពីដើមមកដល់ពេលបច្ចុប្បន្ន* នៅវិចិត្រសាល ១០ Chancery Lane Gallery ទីក្រុងហុងកុង (២០០៩)។

# In The Club
## Ouk Sochivy

Born in Phnom Penh in 1984, Ouk is among the 70% of her nation's population under 30 years of age, raised during the early stages of Cambodia's development and urbanization. She is known for her quintessential evocations of the Khmer youth segment known as Freshies. Described as a style and identity shaped by the requirements for popular televised talent contests, the Freshies notably import globalised beauty and fashion trends from neighboring Asian metropolises.

*In The Club*'s eleven works are narrated by candid titles that offer insight into the characters and customs of Cambodian club culture. Many clubs are equal parts bar, disco, runway, and cabaret, thus fashion and styling is highly integral to the nightlife experience, making everyone from audience to entertainer, a performer.

The artist's direct approach to both her technique and subject matter is a practice passed down by her grandfather, Svay Ken (1933-2009), who is often referred to as the grandfather of contemporary art in Cambodia. While her inheritance continues Svay's goal of keeping a record of everyday Cambodia for generations to come, it departs from the personal stories and objects derived from his personal, sixty tumultuous years of life in Cambodia. Ouk, now 27, paints *her* version of daily life.

Ouk's characters emerge from a range of sources including photos culled from magazines, "research visits" to Phnom Penh's hottest nightspots (Spark, Rock, and Classic), and the artist's imagination. While many of today's well-known figure painters inspired by fashion intend to serve the culture they capture, Ouk's paintings are an extension of the entertainment industry. She acts not only as a painter, but also as a stylist. She outlines poses before proceeding to hairstyles, clothing, accessories, and make-up. Ultimately, her paintings serve as one link in a chain of earnest expressions from a youthculture discovering itself during a highly transitional time.

**About the Artist**
Ouk Sochivy (b. 1984) is a painter best known for her playful, figurative works of Khmer youth. *In The Club* marks the artist's second solo exhibition, following *To Be Continued*, Bophana Audiovisual Resource Centre Gallery, Phnom Penh (2009). Select group exhibitions include *Farmers and Freshies*, Sa Sa Art Gallery, Phnom Penh (2010); and *Forever Until Now*, 10 Chancery Lane Gallery, Hong Kong (2009).

# ក្នុងក្លឹប
## ដោយ  អ៊ុក សុជីវី

# In The Club
## Ouk Sochivy

16 June - 10 July 2011



*Team Dance Girls*, 2011
oil on cotton
60x80cm



*Boy Band*, 2011
oil on cotton
60x80cm